**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមហាផ្ទៃ**

**អគ្គនាយកដ្ឋានរដ្ឋបាល**

លេខ: ៣១០៥...សជណ

ថ្ងៃចន្ទ ១០រោច ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែសីហា ឆ្នាំ២០១៨

**ជម្រាបមក**

**ឯកឧត្តម និងលោកប្រធាននាយកដ្ឋានចំណុះអគ្គនាយកដ្ឋានរដ្ឋបាល**

**កម្មវត្ថុ** : ស្តីពីការជ្រើសរើសនិស្សិតអាហារូបករណ៍ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត ទៅសិក្សានៅប្រទេសជប៉ុនក្រោមគម្រោង (JDS) សម្រាប់ឆ្នាំសិក្សា២០១៩-២០២០។

**យោង** : - លិខិតចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៨ របស់មជ្ឈមណ្ឌលសហប្រតិបត្តិការអន្តរជាតិជប៉ុន(JICE)

- លិខិតលេខ ៤៥ អយក.សជណ ចុះថ្ងៃព្រហស្បតិ៍ ៧កើត ខែទុតិយាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៨ របស់ក្រសួងអប់រំ យុវជន និងកីឡា។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **ឯកឧត្តម** និង **លោកប្រធាន** ថា កម្មវិធីអាហារូបករណ៍សម្រាប់ការអភិវឌ្ឍធនធានមនុស្សក្រោមជំនួយរបស់រដ្ឋាភិបាលជប៉ុន(JDS) បានផ្តល់អាហារូបករណ៍ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ (Master's Degree) រយៈពេល**២ឆ្នាំ** ចំនួន**២៤នាក់** និងថ្នាក់បណ្ឌិត (Ph.D Degree) រយៈពេល**៣ឆ្នាំ** ចំនួន**០២នាក់** ជូនដល់មន្ត្រីរាជការទាំងពីរភេទ ដើម្បីទៅសិក្សានៅប្រទេសជប៉ុនសម្រាប់ឆ្នាំសិក្សា២០១៩-២០២០។ រាល់ការចំណាយលើមធ្យោបាយធ្វើដំណើរទៅមក ថ្លៃសិក្សា ប្រាក់អាហារូបករណ៍ជាបន្ទុករបស់រដ្ឋាភិបាលជប៉ុន។

សម្រាប់ព័ត៌មានលម្អិត និងលក្ខខណ្ឌជ្រើសរើសផ្សេងៗមានដូចខាងក្រោម៖

## I. លក្ខខណ្ឌក្នុងការដាក់ពាក្យ

### ១. ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

បេក្ខជនទាំងពីរភេទត្រូវ៖

- មានសញ្ជាតិខ្មែរ
- មានសញ្ញាបត្របរិញ្ញាបត្រ
- មានអាយុចន្លោះពី២២-៣៩ឆ្នាំ ដោយគិតត្រឹមថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៩ (ថ្ងៃខែឆ្នាំកំណើតគិតចាប់ពីថ្ងៃទី០២ ខែមេសា ឆ្នាំ១៩៧៩ និងថ្ងៃខែឆ្នាំកំណើតមុន ឬត្រឹមថ្ងៃទី០១ ខែមេសា ឆ្នាំ១៩៩៧)
- មានចំណេះដឹងផ្នែកភាសាអង់គ្លេសទាំងការសរសេរ និងនិយាយបានល្អ (មានពិន្ទុTOEFL ៥០០-៥៥០ /IELTS ៥.៥)
- ជាមន្ត្រីរាជការ ឬបុគ្គលិកពេញសិទ្ធិដែលមានបទពិសោធន៍ការងារយ៉ាងតិច**០២ឆ្នាំ** នៅតាមបណ្តាក្រសួងឬស្ថាប័នពាក់ព័ន្ធ(មន្ត្រីជាប់កិច្ចសន្យាមិនត្រូវបានអនុញ្ញាតឡើយ)
- មានសុខភាពល្អបរិបូរណ៍ទាំងកាយសម្បទា និងសតិបញ្ញា។

### ២. ថ្នាក់បណ្ឌិត

បេក្ខជនទាំងពីរភេទត្រូវ៖

- មានសញ្ជាតិខ្មែរ
- បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ (Master Degree) ក្រោមកម្មវិធីអាហារូបករណ៍ JDS

./.

- មានអាយុក្រោម ៤៥ឆ្នាំ គិតដល់ថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៩
- មានបទពិសោធន៍ការងារយ៉ាងតិច០២ឆ្នាំ បន្ទាប់ពីបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ក្រោមកម្មវិធីអាហារូបករណ៍ JDS
- ជាបុគ្គលិករដ្ឋដែលធ្វើការពេញម៉ោងតាមស្ថាប័នពាក់ព័ន្ធដូចមានកំណត់ក្នុង Framework of JDS 2018
- មានសុខភាពល្អបរិបូរណ៍ទាំងកាយសម្បទា និងសតិបញ្ញា។

## II. មុខជំនាញសិក្សា (សម្រាប់ទាំងពីរកម្រិត)

១. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ (Infrastructure Development)
២. ការអភិវឌ្ឍវិស័យឯកជន (Private Sector Development)
៣. ការលើកកម្ពស់គុណភាពអប់រំ (Improvement of Education Quality)
៤. កសិកម្ម និងការអភិវឌ្ឍជនបទ (Agriculture and Rural Development)
៥. ការធ្វើឱ្យប្រសើរឡើងនូវបរិស្ថានរស់នៅក្នុងទីក្រុង (Improvement of Urban Living Environment)
៦. ការធ្វើឱ្យប្រសើរឡើងនៃការថែទាំសុខភាព និងប្រព័ន្ធសន្តិសុខសង្គម (Improvement of Healthcare and Social Security System)
៧. ការធ្វើឱ្យប្រសើរឡើងនូវមុខងាររដ្ឋបាលសាធារណៈ (Improvement of Administrative Functions)
៨. ការអភិវឌ្ឍផ្នែកច្បាប់ និងតុលាការ (Legal and Judicial Development)
៩. ការបង្កើតទំនាក់ទំនងអន្តរជាតិ (Building of International Relations)

## III. កាលបរិច្ឆេទ និងទីកន្លែងទទួលពាក្យ

ចំពោះបេក្ខជនដែលមានបំណងចូលរួមក្នុងកម្មវិធីអាហារូបករណ៍នេះ សូមទាក់ទងរកពាក្យសុំអាហារូបករណ៍ និងបំពេញសំណុំឯកសារផ្សេងៗ ចាប់ពីថ្ងៃផ្សាយដំណឹងនេះរហូតដល់ថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៨ វេលាម៉ោង១៦:៣០នាទីល្ងាច នៅការិយាល័យ JICE-JDS ដែលមានអាសយដ្ឋាន **ជាន់ទី៣ បន្ទប់លេខ៣០៦ អាគារខុនដូអូរ៉ា(AURA Condominium) លេខ៨៧ ផ្លូវលេខ៦៣ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ។**

ពាក្យសុំអាហារូបករណ៍មានចែកជូននៅការិយាល័យ JICE-JDS ឬអាចទាញយកបានតាមរយៈគេហទំព័រដែលមានអាស័យដ្ឋាន: http://jds-scholarship.org/។

- បេក្ខជនត្រូវមានប័ណ្ណសម្គាល់មន្ត្រីរាជការស៊ីវិល ឬលិខិតបញ្ជាក់ពីក្រសួងសាមី
- បេក្ខជនត្រូវដាក់ពាក្យសុំទៅសិក្សាតាមមុខជំនាញដែលពាក់ព័ន្ធនឹងក្រសួងសាមីដូចមានបញ្ជាក់ជូនក្នុងឯកសារភ្ជាប់ជូន (Application Guidelines)
- បេក្ខជនត្រូវឆ្លងកាត់ការពិនិត្យជ្រើសរើសលើសំណុំលិខិត និងធ្វើការសម្ភាសន៍។

សម្រាប់ព័ត៌មានបន្ថែម បេក្ខជនអាចទាក់ទងសួរនៅការិយាល័យ JICE-JDS តាមអាស័យដ្ឋានខាងលើ ឬតាមរយៈទូរស័ព្ទលេខ: ០១២ ៦៨១ ៦១១/ ០២៣ ២១៧ ៩៤៤ អ៊ីម៉ែល: jds.cambodia1@jice.org ឬនៅការិយាល័យអាហារូបករណ៍ និងកម្មសិក្សា នៃនាយកដ្ឋានទំនាក់ទំនងវប្បធម៌ និងអាហារូបករណ៍ អគារលេខ ២៣ ផ្លូវ៣៦០ ខាងកើតស្ថានីយទូរទស្សន៍អប្សរាប្រហែល៥០ម៉ែត្រ។

## IV. កម្មវិធីពន្យល់ណែនាំអំពីអាហារូបករណ៍ (JDS)

បេក្ខជនអាចចូលរួមស្តាប់ការពន្យល់ពីកម្មវិធីអាហារូបករណ៍នេះនៅតាមទីកន្លែង និងកាលបរិច្ឆេទដូចខាងក្រោម៖

១.ថ្ងៃសៅរ៍ ទី១១ ខែសីហា ឆ្នាំ២០១៨ វេលាម៉ោង០៩:០០នាទី ដល់១១:០០នាទីព្រឹក នៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន (CJCC) រាជធានីភ្នំពេញ។

២.ថ្ងៃសៅរ៍ ទី០១ ខែកញ្ញា ឆ្នាំ២០១៨ វេលាម៉ោង០៩:00នាទី ដល់១១:00នាទីព្រឹក នៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន (CJCC) រាជធានីភ្នំពេញ។

៣.ថ្ងៃសៅរ៍ ទី១៨ ខែសីហា ឆ្នាំ២០១៨ វេលាម៉ោង០៩:00នាទី ដល់១១:00នាទីព្រឹក បន្ទប់LH2 នៅសាកលវិទ្យាល័យបាត់ដំបង (University of Battambang-UBB) ខេត្តបាត់ដំបង។

៤.ថ្ងៃសៅរ៍ ទី២៥ ខែសីហា ឆ្នាំ២០១៨ វេលាម៉ោង០៩:00នាទី ដល់១១:00នាទីព្រឹក នៅសណ្ឋាគារមេគង្គ ដលហ្វីន (Mekong Dolphin Hotel) ខេត្តក្រចេះ។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម** និង**លោកប្រធាន** ជ្រាប និងចាត់ចែងផ្សព្វផ្សាយដល់មន្ត្រីរាជការក្រោមឱវាទឱ្យបានទូលំទូលាយតាមការគួរ។

សូម **ឯកឧត្តម** និង**លោកប្រធាន** ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

**អគ្គនាយក**

ច្រាក់ សិរឿន

<u>សូមទំនាក់ទំនង៖</u>

- លោកស្រី នី រតនា
- ទូរស័ព្ទលេខ: ០១៧ ៩៩០ ៩៩៤